ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ:០៤៨ សណន

# សេចក្តីណែនាំ
## ស្តីពី
## ការពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម

ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា កងកម្លាំងនគរបាលជាតិ មន្ត្រីរាជការស៊ីវិលគ្រប់លំដាប់ថ្នាក់ បន្តសម្រេចបានស្នាដៃដ៏ធំធេងក្នុងការចូលរួមថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ដែលជាបុព្វបទសម្រាប់ការអភិវឌ្ឍសង្គមជាតិគ្រប់វិស័យ។ ទន្ទឹមនឹងលទ្ធផលសម្រេចដូចបានលើកឡើងខាងលើ ក្រសួងមហាផ្ទៃបានពិនិត្យឃើញថា ក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ បានលេចចេញនូវបញ្ហាប្រឈមមួយចំនួនទាក់ទងនឹងស្ថានភាពសង្គម ជាពិសេសសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ដែលក្នុងនោះកត់សម្គាល់ការគ្រប់គ្រងស្ថានការណ៍បទល្មើស អំពើជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ អំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងជួញដូរផ្លូវភេទ ការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ បទល្មើសបច្ចេកវិទ្យា និងអំពើឆបោកតាមអនឡាញ ការគ្រប់គ្រងជនបរទេស ការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក បញ្ហាក្មេងទំនើង ជាដើម។

អាស្រ័យហេតុនេះ ក្នុងគោលបំណងពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមឱ្យកាន់តែល្អប្រសើរ បម្រើដល់ការអភិវឌ្ឍប្រទេសជាតិ និងភាពសុខដុមរមនានៅក្នុងសង្គម ប្រជាពលរដ្ឋរស់នៅប្រកបដោយភាពសុខសាន្ត ចូលរួមអនុវត្តដោយជោគជ័យយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងដើម្បីអនុវត្តឱ្យបានសម្រេចតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងមហាផ្ទៃដាក់ចេញនូវវិធានការចាំបាច់សំខាន់ៗមួយចំនួនដូចខាងក្រោម៖

### ១. ការអនុវត្តគោលនយោបាយ «ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព»

- យកចិត្តទុកដាក់ក្នុងការពង្រឹង និងគ្រប់គ្រងឱ្យបានស្ថានការណ៍បទល្មើសគ្រប់ប្រភេទតាមរយៈការជំរុញអនុវត្តគោលនយោបាយ «ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព» ដោយត្រូវខិតខំបង្កើនសកម្មភាពបង្ការ ទប់ស្កាត់ ព្រមទាំងស្រាវជ្រាវរកឱ្យឃើញ និងបង្ក្រាបបទល្មើសដែលកើតឡើងឱ្យបានទាន់ពេលវេលា ជាពិសេសអំពើលួច ឆក់ ប្លន់ អំពើឃាតកម្ម អំពើបង្ខាំងមនុស្សជំរិតទារប្រាក់ អំពើជួញដូរមនុស្សតាមគ្រប់ទម្រង់ ល្បែងស៊ីសងខុសច្បាប់ឱ្យមានប្រសិទ្ធភាព សំដៅធ្វើឱ្យបទល្មើសមានការថយចុះបន្ថែមទៀត។

- រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវយកចិត្តទុកដាក់ក្នុងការផ្សព្វផ្សាយអប់រំ ការរៀបចំវេទិកាសាធារណៈ ដើម្បីទទួលសំណើ សំណូមពរផ្សេងៗ សំដៅកៀរគរការចូលរួមគាំទ្រពីសំណាក់ប្រជាពលរដ្ឋគ្រប់ស្រទាប់ជាន់ថ្នាក់ ក្នុងការអនុវត្តឱ្យបានសម្រេចជោគជ័យគោលនយោបាយ«*ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព*»។

**២. ការប្រយុទ្ធប្រឆាំងការជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀន**

ត្រូវបើកយុទ្ធនាការប្រយុទ្ធប្រឆាំងការជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ តាមវិធានការសំខាន់ៗមួយចំនួន៖

- បង្កើនការផ្សព្វផ្សាយអប់រំច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន តាមរយៈការជួបអប់រំផ្សព្វផ្សាយដោយផ្ទាល់តាមសហគមន៍ គ្រឹះស្ថានសិក្សា រោងចក្រសហគ្រាស ទីតាំងអាជីវកម្មនានា គ្រឹះស្ថានសាធារណៈ និងតាមរយៈប្រព័ន្ធឃោសនារបស់រដ្ឋ និងឯកជន ដើម្បីឱ្យសាធារណជនកាន់តែយល់ជ្រួតជ្រាបអំពីច្បាប់ និងឥទ្ធិពលគ្រោះថ្នាក់ដែលបណ្ដាលមកពីការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ចំពោះខ្លួនផ្ទាល់ ក្រុមគ្រួសារ សហគមន៍ និងសង្គមជាតិទាំងមូល ក្នុងគោលដៅកៀរគរការចូលរួមគាំទ្រមិនប្រើប្រាស់ និងការប្រយុទ្ធប្រឆាំងការជួញដូរ ការចែកចាយគ្រឿងញៀនខុសច្បាប់។

- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធជំរុញការអនុវត្តច្បាប់ និងវិធានការរដ្ឋបាលឱ្យបានម៉ឺងម៉ាត់ ដើម្បីស៊ើបអង្កេត ស្រាវជ្រាវ និងផ្ដន្ទាទោសឱ្យបានម៉ឺងម៉ាត់បណ្ដាញអង្គការចាត់តាំងនៃក្រុមឧក្រិដ្ឋជនគ្រឿងញៀន។ ខិតខំក្ដាប់អំពីឧបាយកល សកម្មភាពទំនាក់ទំនង របៀបដឹកជញ្ជូន ព្រមទាំងលុបបំបាត់សកម្មភាពជួញដូរ ចែកចាយប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ដើម្បីកាត់ផ្ដាច់ចរាចរគ្រឿងញៀនខុសច្បាប់ និងបង្ក្រាបឱ្យដល់ឫសគល់ប្រកបដោយប្រសិទ្ធភាព។

- សហការជាមួយក្រសួង ស្ថាប័នជំនាញដើម្បីគ្រប់គ្រងឱ្យបានការនាំចូល ការប្រើប្រាស់សារធាតុគីមីផ្សំក្នុងគោលដៅទប់ស្កាត់ និងរកឃើញទាន់ពេលវេលាការឆ្លៀតប្រើប្រាស់សារធាតុគីមីផ្សំទាំងនោះ ដើម្បីលបលួចផលិតគ្រឿងញៀនសំយោគខុសច្បាប់។

- យកចិត្តទុកដាក់គ្រប់គ្រង និងលុបបំបាត់ឱ្យបានជាដាច់ខាតការប្រើប្រាស់គ្រឿងញៀនខុសច្បាប់នៅក្នុងរង្គសាល ក្លឹបកម្សាន្ត កាស៊ីណូ សណ្ឋាគារ។ល។ ត្រូវមានវិធានការធ្វើកិច្ចសន្យាជាមួយបណ្ដាទីតាំងទាំងនោះហាមការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ក្នុងករណីរកឃើញមានការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ត្រូវមានវិធានការរដ្ឋបាល វិធានការច្បាប់ជាមួយទីតាំងទាំងនោះ។

- ខិតខំប្រមូលផ្ដុំលើកកម្ពស់សមត្ថភាព លទ្ធភាពគ្រប់គ្រង ព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀនឱ្យបានប្រសើរថែមទៀត ដើម្បីទប់ស្កាត់ការរីករាលដាលអ្នកញៀនគ្រឿងញៀនឈានទៅលុបបំបាត់ទីផ្សារគ្រឿងញៀនខុសច្បាប់។

- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គភាពប្រឆាំងគ្រឿងញៀនរបស់ប្រទេសជាដៃគូឱ្យបានទូលំទូលាយ ដើម្បីមានព័ត៌មានគ្រប់គ្រាន់បម្រើឱ្យការបង្ក្រាប ការបង្ការទប់ស្កាត់ពីចម្ងាយ និងដកបទពិសោធន៍ពីគ្នាទៅវិញទៅមក។

## ៣. ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ការជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទតាមគ្រប់ទម្រង់

បង្កើនការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ការជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទតាមគ្រប់ទម្រង់ ដោយផ្តោតលើវិធានការសំខាន់ៗមួយចំនួនៈ

- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធជំរុញការផ្សព្វផ្សាយអប់រំដល់សាធារណជន ជាពិសេសជនងាយរងគ្រោះ ដើម្បីលើកកម្ពស់ការយល់ដឹងពីល្បិចកល សកម្មភាពរបស់ពួកឧក្រិដ្ឋជន យល់ដឹងពីច្បាប់ស្តីពីការប្រឆាំងការជួញដូរមនុស្ស និងកម្លាំងពលកម្ម ច្បាប់ស្តីពីអន្តោប្រវេសន៍ និងលិខិតបទដ្ឋានគតិយុត្តចាំបាច់នានា សំដៅគាំទ្រការប្រយុទ្ធប្រឆាំង និងចូលរួមអនុវត្តច្បាប់ឱ្យបានល្អ។

- កំណត់អត្តសញ្ញាណ និងគ្រប់គ្រងបណ្តាគោលដៅ ទីតាំងដែលអាចសន្មត់ជាកន្លែងប្រព្រឹត្តបទល្មើសជួញដូរមនុស្ស ជួញដូរពលកម្ម ឬជួញដូរផ្លូវភេទ ដោយតម្រូវឱ្យម្ចាស់គោលដៅ ទីតាំងទាំងនោះធ្វើកិច្ចសន្យាជានាមិនឱ្យកើតមានបទល្មើសខាងលើ ដោយត្រូវបង្កើនការគ្រប់គ្រង ត្រួតពិនិត្យជាប្រចាំ ករណីមានបទល្មើសកើតឡើងត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់វិធានការរដ្ឋបាល ឬវិធានការច្បាប់ យោងតាមកម្រិតបទល្មើសជាក់ស្តែង។

- ពង្រឹងវិធានការគ្រប់គ្រង និងត្រួតពិនិត្យសកម្មភាពទីភ្នាក់ងារជ្រើសរើសពលករទៅធ្វើការនៅបរទេស ដើម្បីតម្រង់ទិសអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ និងគោលការណ៍នានា ព្រមទាំងបង្ការទប់ស្កាត់ និងរកឃើញទាន់ពេលនូវសកម្មភាពនានាពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ឬជួញដូរពលកម្ម។

- ជំរុញការស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបឱ្យបានម៉ឺងម៉ាត់អំពើជួញដូរមនុស្ស ជួញដូរពលកម្ម អាជីវកម្មផ្លូវភេទតាមគ្រប់ទម្រង់ ការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ អំពើឆបោកតាមប្រព័ន្ធអនឡាញ បទល្មើសបង្ខាំងមនុស្សខុសច្បាប់ ការចាប់ជំរិតទារប្រាក់ ការបង្ខំឱ្យធ្វើពលកម្ម ដោយចាប់ឃាត់ខ្លួនមេខ្លោង និងបក្ខពួកយកទៅផ្តន្ទាទោសតាមច្បាប់ និងសង្គ្រោះជនរងគ្រោះឱ្យបានទាន់ពេលវេលា។

- បង្កើនកិច្ចសហការជាលក្ខណៈអន្តរជាតិ ជាពិសេសជាមួយប្រទេសជិតខាងដើម្បីផ្លាស់ប្តូរព័ត៌មានឱ្យបានទាន់ពេលវេលា និងសហការក្នុងការស្រាវជ្រាវស៊ើបអង្កេត បង្ក្រាបពួកមេខ្លោង ខ្សែរយៈពាក់ព័ន្ធនឹងការជួញដូរមនុស្ស ការជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ។

## ៤. ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ

- ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានម៉ឺងម៉ាត់ច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ។ ត្រូវបង្កើនការអប់រំ លើកកម្ពស់ការយល់ដឹង និងការចូលរួមពីសំណាក់ប្រជាពលរដ្ឋក្នុងការផ្តល់ព័ត៌មានដល់អាជ្ញាធរមានសមត្ថកិច្ច ពាក់ព័ន្ធនឹងការប្រើប្រាស់អាវុធ គ្រឿងផ្ទុះដោយខុសច្បាប់ ឬសង្ស័យទាក់ទងដល់ការចរាចរជួញដូរអាវុធ គ្រឿងផ្ទុះ។

- ពង្រឹងយន្តការគ្រប់គ្រងស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃក្នុងគោលដៅដើម្បីមានវិធានការឱ្យបានច្បាស់លាស់ក្នុងការតាមដានត្រួតពិនិត្យការនាំចូល ការផលិត ការផ្គត់ផ្គង់ ការចែកចាយរំសេវផ្ទុះ។ អគ្គស្នងការដ្ឋាននគរបាលជាតិសហការជាមួយរដ្ឋបាលរាជធានី ខេត្ត ធ្វើបច្ចុប្បន្នភាពឡើងវិញ

ក្រុមហ៊ុនដែលកំពុងដំណើរការផលិតរំសេវផ្ទុះ បម្រើឱ្យសេវាកម្មសាធារណៈ និងវិស្វកម្មស៊ីវិល ព្រមទាំងត្រូវធ្វើបច្ចុប្បន្នភាពការដ្ឋានដែលពាក់ព័ន្ធនឹងការប្រើប្រាស់រំសេវផ្ទុះ ដូចជាការដ្ឋានវាយថ្ម ការដ្ឋានរុករករ៉ែផ្សេងៗ។ ត្រូវយកចិត្តទុកដាក់ក្នុងការចុះបញ្ជីគ្រប់គ្រងការបញ្ចេញ ការបញ្ចូល ការកាត់ស្តុករំសេវជាតិផ្ទុះ និងណែនាំការដាក់ផ្ទុះឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។

- ត្រូវពង្រឹងការចុះបញ្ជីគ្រប់គ្រងអាវុធ និងគ្រាប់រំសេវ ត្រួតពិនិត្យឡើងវិញរាល់អាវុធ គ្រាប់ដែលបានចុះបញ្ជី អនុវត្តឱ្យបានត្រឹមត្រូវក្នុងការផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធខ្លីយកតាមខ្លួន និងការផ្តល់ប័ណ្ណសម្គាល់អាវុធវែងខ្លីសម្រាប់ប្រើប្រាស់ក្នុងអង្គភាពឱ្យបានត្រឹមត្រូវតាមស្មារតីអនុក្រឹត្យលេខ ១៥៨ អនក្រ ស្តីពីនីតិវិធី និងលក្ខខណ្ឌការគ្រប់គ្រង ការប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវរបស់កងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ ស្ថាប័នសាធារណៈ និងមន្ត្រី។ យកចិត្តទុកដាក់គ្រប់គ្រង និងការពារឃ្លាំងសុវត្ថិភាពអាវុធ គ្រឿងផ្ទុះ រៀបចំទុកដាក់ ថែរក្សា ការពារអាវុធ គ្រឿងផ្ទុះឱ្យបានគត់មត់។ ចាត់តាំងអនុវត្តវិធានការត្រួតពិនិត្យរដ្ឋបាលឱ្យបានញឹកញាប់ ដើម្បីត្រួតពិនិត្យរកឃើញការប្រើប្រាស់អាវុធ គ្រឿងផ្ទុះដោយខុសច្បាប់។

- រដ្ឋបាលរាជធានី ខេត្តទាំងអស់ត្រូវចាត់ឱ្យមានការធ្វើបច្ចុប្បន្នភាពឡើងវិញក្លឹប ឬទីលានសម្រាប់ហាត់បាញ់ ទាំងរបស់រដ្ឋ និងឯកជន ស្នើមកក្រសួងមហាផ្ទៃ ដើម្បីស្នើសុំរាជរដ្ឋាភិបាលក្នុងការកំណត់ចំនួនក្លឹបឬទីលានហាត់បាញ់ឱ្យបានសមស្រប។ ចំពោះមុខត្រូវពង្រឹងការគ្រប់គ្រងក្លឹប ឬទីលានហាត់បាញ់ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងធានាសុវត្ថិភាពសាធារណៈ។

- ខិតខំស្រាវជ្រាវ និងលុបបំបាត់ឱ្យបានទីផ្សារលួចលក់អាវុធ គ្រាប់រំសេវ។

- អគ្គស្នងការដ្ឋាននគរបាលជាតិត្រូវប្រមូលទិន្នន័យពាក់ព័ន្ធទៅនឹងការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ដើម្បីសិក្សា រៀបចំធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាឱ្យឆ្លើយតបទៅនឹងស្ថានភាពប្រែប្រួលរីកចម្រើនរបស់សង្គមជាតិ។

**៥. ការងារគ្រប់គ្រងជនបរទេស**

- ត្រូវយកចិត្តទុកដាក់ក្នុងការចុះបញ្ជីគ្រប់គ្រងការស្នាក់នៅរបស់ជនបរទេសតាមខ្នងផ្ទះ គោលដៅអាជីវកម្ម សេវាកម្ម រោងចក្រ សហគ្រាស កាស៊ីណូ សណ្ឋាគារ ភោជនីយដ្ឋាន ដែនកោះ ដើម្បីគ្រប់គ្រងនិងក្តាប់បានអំពីវត្តមានពិតប្រាកដរបស់ជនបរទេសដោយត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ច្បាប់ស្តីពីអន្តោប្រវេសន៍។

- បន្តពង្រឹងការគ្រប់គ្រងការចេញ-ចូលប្រទេសឱ្យមានប្រសិទ្ធភាព សំដៅបង្ការ ទប់ស្កាត់ការជ្រៀតចូលនៃពួកភេរវជន ឧក្រិដ្ឋជនឆ្លងដែន មុខសញ្ញាគេចពីសំណាញ់ច្បាប់នៃបណ្តាប្រទេសដទៃ និងបង្ការ ទប់ស្កាត់ការជ្រៀតចូលមកស្នាក់នៅខុសច្បាប់របស់ជនបរទេសតាមច្រករបៀង និងច្រកសមុទ្រ។

- បន្តសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចុះធ្វើការត្រួតពិនិត្យ និងចុះបញ្ជីហត្ថពលករបរទេសនៅតាមគោលដៅអាជីវកម្ម សេវាកម្ម រោងចក្រ សហគ្រាស ការដ្ឋាន កាស៊ីណូ សណ្ឋាគារ រមណីយដ្ឋាន ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវម៉ត់ចត់ច្បាប់ស្តីពីការងារ។

- យកចិត្តទុកដាក់អនុវត្តវិធានការស្រាវជ្រាវ ស៊ើបអង្កេតសំដៅស្វែងរកជនបរទេសប្រព្រឹត្តល្មើសច្បាប់ស្តីពីអន្តោប្រវេសន៍ និងច្បាប់ពាក់ព័ន្ធផ្សេងទៀត ដើម្បីអនុវត្តនីតិវិធីបណ្តេញចេញ ឬនីតិវិធីតុលាការ។

**៦. ការងារអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងគ្រប់គ្រងសណ្តាប់ធ្នាប់សាធារណៈ**

- រឹតបន្តឹងការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដោយត្រូវកាត់បន្ថយឱ្យបានជាអតិបរមាគ្រោះថ្នាក់ចរាចរណ៍តាមរយៈការអនុវត្តដោយយកចិត្តទុកដាក់ និងម៉ឺងម៉ាត់បំផុតចំពោះអ្នកបើកបរយានយន្តគ្មានប័ណ្ណបើកបរ អ្នកបើកបរយានយន្តមានជាតិស្រវឹង ឬនៅក្រោមឥទ្ធិពលគ្រឿងញៀន ប្រើប្រាស់ល្បឿនហួសកំរិត មិនពាក់មួកសុវត្ថិភាព មិនគោរពភ្លើងសញ្ញាចរាចរណ៍ ដឹកជញ្ជូនលើសចំណុះ ឬសំពីងសំពោងខុសបទដ្ឋានបច្ចេកទេស។ ត្រូវពង្រឹងក្រុមចល័តដែលមានភារកិច្ចត្រួតពិនិត្យបទល្មើសចរាចរណ៍ឱ្យចុះធ្វើសកម្មភាពនៅតាមគោលដៅស្មុគស្មាញ ដែលមានហានិភ័យចំពោះសុវត្ថិភាពចរាចរណ៍តាមផ្លូវជាតិសំខាន់ៗ។

- ចាត់វិធានការក្នុងការដោះស្រាយសណ្តាប់ធ្នាប់សាធារណៈតាមដងផ្លូវ ទីសាធារណៈ និងទីប្រជុំជន ច្រកចេញចូលទីក្រុង ដើម្បីបញ្ចៀសការកកស្ទះ និងភាពអនាធិបតេយ្យ ការចតយានយន្តលយចូលផ្លូវសាធារណៈ ការតាំងលក់ទំនិញផ្សេងៗលើចិញ្ចើមផ្លូវ ការដ្ឋានសំណង់បំពានលើចិញ្ចើមផ្លូវ និងផ្លូវសាធារណៈ។ បង្កើនប្រសិទ្ធភាពគោរពច្បាប់ចរាចរណ៍ផ្លូវគោកដោយត្រូវផ្សព្វផ្សាយ អប់រំ ដើម្បីបង្កើនការយល់ដឹងពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកគ្រប់រូបភាព គ្រប់ទីកន្លែង គិតទាំងនៅតាមសហគមន៍ គ្រឹះស្ថានសិក្សា គ្រឹះស្ថានសាធារណៈ និងតាមប្រព័ន្ធឃោសនានានារបស់រដ្ឋ និងឯកជន។

- មន្ត្រីអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកគ្រប់លំដាប់ថ្នាក់ ត្រូវធ្វើជាគំរូក្នុងការអនុវត្តច្បាប់ មានសីលធម៌ អាកប្បកិរិយាសមរម្យ ត្រូវលុបបំបាត់ឱ្យបាននូវអំពើអសកម្មផ្សេងៗ ទន្ទឹមនឹងនោះខិតខំលុបបំបាត់វប្បធម៌អន្តរាគមន៍ក្នុងគោលដៅជានាកិត្តិយស សេចក្តីថ្លៃថ្នូររបស់កងកម្លាំងអនុវត្តច្បាប់។

**៧. ការប្រយុទ្ធប្រឆាំងបទល្មើសបច្ចេកវិទ្យា**

ត្រូវបង្កើនការក្តាប់សភាពការណ៍ និងព័ត៌មានទាក់ទងនឹងបទល្មើសបច្ចេកវិទ្យា អំពើឆបោកតាមអនឡាញ ជាពិសេសល្បែងអនឡាញខុសច្បាប់គ្រប់ប្រភេទដើម្បីមានវិធានការស្រាវជ្រាវ បង្ក្រាបឱ្យបានទាន់ពេលវេលា និងមានវិធានការបង្ការ អប់រំដល់សាធារណជនទាំងអស់បានយល់ជ្រួតជ្រាបអំពីល្បិចកល វិធីសាស្ត្រនៃការបោកបញ្ឆោតរបស់ពួកប្រព្រឹត្តបទល្មើស។

**៨. ការងារគ្រប់គ្រងពន្ធនាគារ**

- ត្រូវយកចិត្តទុកដាក់ក្នុងការគ្រប់គ្រង និងអនុវត្តឱ្យបានម៉ឺងម៉ាត់នូវច្បាប់ នីតិវិធី និងបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ។ ទន្ទឹមនោះត្រូវធ្វើការសិក្សា រៀបចំបែងចែកប្រភេទជនជាប់ឃុំដាក់ដោយឡែកពីគ្នាតាមចំណាត់ថ្នាក់សន្តិសុខ អ្នកជាប់ទោសឧក្រិដ្ឋ និងបទល្មើសគ្រឿងញៀន ក្នុងគោលដៅគ្រប់គ្រងឱ្យបានម៉ឺងម៉ាត់តាមប្រភេទ និងផ្តាច់ទំនាក់ទំនងពីមជ្ឈដ្ឋានខាងក្រៅ។

- ពង្រឹងការងារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ពន្ធនាគារ ពង្រឹងវិធានការទប់ស្កាត់ការបង្កហានិភ័យផ្នែកសន្តិសុខ សណ្តាប់ធ្នាប់ យកចិត្តទុកដាក់ក្តាប់មុខសញ្ញាជនជាប់ឃុំដែលជាមេខ្លោង ដើម្បីមានវិធានការ

រាំងស្កាត់ទំនាក់ទំនងរបស់ក្រុមនេះទៅក្នុងផ្ទៃក្នុងជនជាប់ឃុំ ទំនាក់ទំនងទៅខាងក្រៅ និងទំនាក់ទំនងពីក្រៅចូលមកក្នុង ពាក់ព័ន្ធនឹងការចរាចរគ្រឿងញៀនខុសច្បាប់ ឬការប៉ុនប៉ងលួចរត់ ឬរំដោះមេខ្លោងជនជាប់ឃុំ។

- យកចិត្តទុកដាក់ពង្រឹងកិច្ចការពារជនជាប់ឃុំ ពេលដឹកជញ្ជូនទៅកាន់សវនាការគ្រប់ជាន់ថ្នាក់ ឬទៅពិនិត្យ និងព្យាបាលជំងឺនៅមន្ទីរពេទ្យ។ ចំពោះគ្រួសារសាច់ញាតិចេញចូលសាកសួរសុខទុក្ខជនជាប់ឃុំ ក៏ត្រូវយកចិត្តទុកដាក់ក្នុងការឆែកឆេរ និងមានវិធានការគ្រប់គ្រងឱ្យបានម៉ឺងម៉ាត់បំផុត។

- ខិតខំសហការជាមួយក្រសួងយុត្តិធម៌ក្នុងការអនុវត្តយន្តការអាទិភាពចាំបាច់ ដើម្បីដោះស្រាយភាពចង្អៀតណែនរបស់ជនជាប់ឃុំក្នុងពន្ធនាគារ និងបន្តពិនិត្យ សិក្សារៀបចំក្របខ័ណ្ឌនានាសម្រាប់គាំទ្រដល់ការបង្កើតមជ្ឈមណ្ឌលអប់រំកែប្រែទណ្ឌិតបទល្មើសគ្រឿងញៀន និងទណ្ឌិតបទល្មើសនានា។

- បន្តលើកកម្ពស់ការអនុវត្តកម្មវិធីអប់រំកែប្រែ និងស្តារនីតិសម្បទា កម្មវិធីអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងមុខរបរ កម្មវិធីសមាហរណកម្ម និងកម្មវិធីសេវាសុខភាពពន្ធនាគារ។

- លើកកម្ពស់គុណភាព សមត្ថភាព សីលធម៌ វិជ្ជាជីវៈរបស់មន្ត្រីគ្រប់គ្រងពន្ធនាគារ ក្នុងគោលដៅគ្រប់គ្រងពន្ធនាគារ និងគ្រប់គ្រងជនជាប់ឃុំឱ្យកាន់តែមានប្រសិទ្ធភាព ត្រូវអនុវត្តវិធានការរដ្ឋបាល ឬវិធានការច្បាប់ឱ្យបានម៉ឺងម៉ាត់ចំពោះមន្ត្រីពន្ធនាគារ ឬអនុរក្សដែលមានការពាក់ព័ន្ធការប្រព្រឹត្តបទល្មើសក្នុងពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែ។ យកចិត្តទុកដាក់ពង្រឹងការងារអធិការកិច្ចផ្ទៃក្នុងតាមរយៈការចុះត្រួតពិនិត្យការអនុវត្តនីតិវិធីគ្រប់គ្រងពន្ធនាគារជាប្រចាំ។

**៩. ការបង្ការទប់ស្កាត់ បង្ក្រាបសកម្មភាពក្មេងទំនើង**

- ត្រូវខិតខំលុបបំបាត់នូវសកម្មភាពក្មេងទំនើងនៅក្នុងសង្គម។ ចំពោះមុខនេះត្រូវតម្លើងបញ្ជីមុខសញ្ញាក្មេងទំនើងនៅតាមមូលដ្ឋាននីមួយៗ និងត្រូវបែងចែកប្រភេទក្មេងទំនើង អ្នកដែលមានអាណាព្យាបាលគ្រប់គ្រង អ្នកដែលត្រូវសាច់ញាតិបោះបង់ចោល អ្នកដែលងាយរងគ្រោះដើម្បីមានវិធានការអប់រំ និងគ្រប់គ្រងឱ្យបានច្បាស់លាស់។

- យកចិត្តទុកដាក់ក្នុងការសហការជាមួយអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីលើកកម្ពស់ការចូលរួមទាំងអស់គ្នាក្នុងការអប់រំក្មេងទំនើង ខិតខំសិក្សាក្នុងការបង្កើតព្រឹត្តិការណ៍ផ្សេងៗដូចជាសិល្បៈ កីឡា ឬការងារជាក់លាក់តាមលទ្ធភាពជាក់ស្តែងរបស់មូលដ្ឋាននីមួយៗ ក្នុងគោលដៅធ្វើសមាហរណកម្មក្មេងទំនើងទាំងនោះទៅតាមចំណង់ចំណូលចិត្តរបស់ពួកគេ ទៅក្នុងព្រឹត្តិការណ៍ ឬការដ្ឋានការងារទាំងនោះ។

- ទន្ទឹមនឹងវិធានការអប់រំ ក៏ត្រូវយកចិត្តទុកដាក់ក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបរាល់សកម្មភាពក្មេងទំនើងដែលបង្កឱ្យមានគ្រោះភ័យនៅក្នុងសង្គម ដោយត្រូវអនុវត្តវិធានការច្បាប់ឱ្យបានម៉ឺងម៉ាត់ផងដែរ។

**១០.** យកចិត្តទុកដាក់ជំរុញការងារសាធារណមតិ ដោយត្រូវបង្កើនឱ្យមានវេទិកាផ្សព្វផ្សាយឱ្យបានទូលំទូលាយតាមគ្រប់រូបភាព និងជាបន្តបន្ទាប់ ទាំងអង្គភាពប្រតិបត្តិការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អំពីលទ្ធផលនៃកិច្ចប្រតិបត្តិការស្រាវជ្រាវ បង្ក្រាបបទល្មើសឧក្រិដ្ឋធំៗដែលកន្លងមកធ្វើឱ្យជះឥទ្ធិពលដល់ចិត្តសាស្ត្រ និងភាពភ័យខ្លាចនៅក្នុងសង្គម។

-អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ និងគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំផែនការសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីដឹកនាំតម្រង់ទិសសមត្ថកិច្ចក្រោមឱវាទ ចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធភាព។

-រៀងរាល់សប្តាហ៍ត្រូវបូកសរុប រាយការណ៍លទ្ធផល បញ្ហាប្រឈម និងទិសដៅជូនមកក្រសួងមហាផ្ទៃ។ រៀងរាល់ខែត្រូវធ្វើការប្រជុំបូកសរុប ដកពិសោធន៍ និងដាក់ចេញវិធានការបន្ត។ ក្រសួងមហាផ្ទៃនឹងធ្វើការប្រជុំបូកសរុប ដកពិសោធន៍ក្នុងក្របខ័ណ្ឌទូទាំងប្រទេសរៀងរាល់៣ខែម្តង។

ទទួលបានសេចក្តីណែនាំនេះ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ គណៈអភិបាលរាជធានី ខេត្ត អង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ត្រូវចាត់តាំងអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់ និងប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ អង្គារ ៤រោច ខែ ភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- អគ្គនាយកដ្ឋានរដ្ឋបាល
- អគ្គនាយកដ្ឋានអន្តោប្រវេសន៍
- អគ្គនាយកដ្ឋានពន្ធនាគារ
- អគ្គនាយកដ្ឋានបច្ចេកវិទ្យាឌីជីថល និងផ្សព្វផ្សាយអប់រំ
- អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ